មជ្ឈមណ្ឌលកម្ពុជា 4.0
CAMBODIA 4.0 CENTER
Inspire Empower Succeed

Article
March 2021

# បច្ចេកវិទ្យា និងវិស័យឧស្សាហកម្មវៃឆ្លាតនៅកម្ពុជា

នៅក្នុងយុគសម័យបដិវត្តន៍ឧស្សាហម្ម៤.0 បច្ចេកវិទ្យាឌីជីថលបានដើរតួនាទីដ៏សំខាន់ក្នុងការកសាងគ្រឹះសេដ្ឋកិច្ច និងសង្គមឌីជីថល។ ដោយផ្តើមចេញពីបដិវត្តន៍ឧស្សាហកម្ម ៤.0 ឧស្សាហកម្មវៃឆ្លាតបានលេចចេញជារូបរាងឡើង ដោយក្នុងនោះបច្ចេកវិទ្យាបានចូលរួមយ៉ាងសកម្មនៅក្នុងប្រតិបត្តិការផលិត និងគ្រប់គ្រងខ្សែច្រវាក់ផលិតកម្ម ដោយជម្រុញប្រសិទ្ធភាព កាត់បន្ថយការខូចខាត ក៏ដូចជាហានិភ័យផ្សេងៗ ដែលធ្វើឲ្យផលិតផលមានគុណភាពកាន់តែល្អប្រសើរ ចំណេញពេលវេលា និងមានថ្លៃដើមផលិតទាបជាងមុន។ សម្រាប់សហគ្រាសធុនតូច និងមធ្យម វត្តមានរបស់ស្វ័យប្រវត្តិកម្មនៅក្នុងផលិតកម្មតាមរយៈឧស្សាហកម្ម ៤.0 នឹងធ្វើឱ្យតម្រូវការនៃការផលិតកើនឡើង ដែលទាមទារឱ្យមានការយកចិត្តទុកដាក់ក្នុងការសម្របខ្លួនជាមួយការមកដល់នៃបដិវត្តន៍ឧស្សាហកម្ម ជាពិសេសរោងចក្រផលិតខ្នាតមធ្យមនឹងកាន់តែមានសក្តានុពលក្នុងការតភ្ជាប់ជាមួយខ្សែច្រវាក់ផ្គត់ផ្គង់នៅថ្នាក់តំបន់ និងសកលលោក។

ស្របពេលជាមួយគ្នានេះដែរ ក្រៅពីបច្ចេកវិទ្យាឌីជីថល ជំនាញឌីជីថលក៏មានភាពចាំបាច់ផងដែរក្នុងការធានាឲ្យបានថាភាគីពាក់ព័ន្ធទាំងអស់មានចំណេះដឹង និងជំនាញគ្រប់គ្រាន់ក្នុងការទាញយកប្រយោជន៍ពីការប្រើប្រាស់បច្ចេកវិទ្យាឱ្យអស់ពីលទ្ធភាព និងឆ្ពោះទៅរកការបង្កើតថ្មីដោយខ្លួនឯង។

ខាងក្រោមនេះ គឺជាសម្រង់បច្ចេកវិទ្យាឌីជីថល និងជំនាញឌីជីថលមួយចំនួន ដែលមានសក្តានុពលនៅក្នុងវិស័យឧស្សាហកម្មវៃឆ្លាតនៅកម្ពុជា៖

## I. បច្ចេកវិទ្យាឌីជីថល

| ល.រ | បច្ចេកវិទ្យាឌីជីថល | ការអនុវត្ត | រូបតំណាង |
|---|---|---|---|
| ១ | Industrial Internet of Things (IIoT) | IIoT ត្រូវបានប្រទេសមួយចំនួនដូចជាប្រទេសបារាំង, ប្រទេសអូស្ត្រាលី, ប្រទេសជប៉ុន និងប្រទេសអង់គ្លេសប្រើប្រាស់សម្រាប់គ្រប់គ្រងស្តុកទំនិញ។ |  |

| ល.រ | បច្ចេកវិទ្យាឌីជីថល | ការអនុវត្ត | រូបតំណាង |
|---|---|---|---|
| ២ | Cloud computing | Cloud computing ត្រូវបានប្រទេសភាគច្រើននៅទូទាំងពិភពលោករួមមានប្រទេសជប៉ុន, ប្រទេសអូស្ត្រាលី, សហរដ្ឋអាមេរិក, សហភាពអឺរ៉ុប, និងប្រទេសសិង្ហបុរីប្រើប្រាស់សម្រាប់ផ្ទុកទិន្នន័យប្រព័ន្ធផលិតកម្ម។ |  |
| ៣ | Additive manufacturing (AM) / 3D Printing | ប្រទេសឥណ្ឌា, ប្រទេសចិន, ប្រទេសបារាំង, ប្រទេសអាឡឺម៉ង់ និងប្រទេសជប៉ុនប្រើប្រាស់បច្ចេកវិទ្យានេះសម្រាប់ឌីសាញ ឬបោះពុម្ពផលិតផល ដែលវាអាចជួយកាត់បន្ថយថ្លៃដើមផលិត។ |   |
| ៤ | Big Data & Analytics | ដោយប្រើឧបករណ៍ចាប់សញ្ញា ទិន្នន័យត្រូវបានប្រមូល រួចវិភាគ និងជូនដំណឹងនៅពេលផលិតកម្មមានការរាំងស្ទះ។ ប្រទេសភាគច្រើនបាននឹងកំពុងប្រើប្រាស់បច្ចេកវិទ្យានេះរួមមានសហរដ្ឋអាមេរិក, ប្រទេសចិន, ប្រទេសជប៉ុន, ប្រទេសឥណ្ឌា, ប្រទេសកាណាដា, និងប្រទេសកូរ៉េខាងត្បូង។ |   |
| ៥ | Sensors | សហភាពអឺរ៉ុប, ប្រទេសឥណ្ឌា, ប្រទេសចិន, ប្រទេសជប៉ុន, និងប្រទេសកូរ៉េខាងត្បូងប្រើប្រាស់បច្ចេកវិទ្យានេះសម្រាប់ការប្រមូលទិន្នន័យ និងការត្រួតពិនិត្យដំណើរការផលិតកម្ម។ |  |

| ល.រ | បច្ចេកវិទ្យាឌីជីថល | ការអនុវត្ត | រូបតំណាង |
|---|---|---|---|
| ៦ | Cognitive Computing | បច្ចេកវិទ្យានេះត្រូវបានសហភាពអឺរ៉ុប និងសហរដ្ឋអាមេរិកប្រើប្រាស់ដោយ ក្នុងនោះឧបករណ៍ចាប់សញ្ញានឹងប្រមូលទិន្នន័យ និងវិភាគបញ្ហា ដើម្បីបង្កើនប្រសិទ្ធភាពផលិតកម្ម ដោយកាត់បន្ថយចំណាយ និងចំណេញពេលវេលា ។ |  |
| ៧ | Virtual Reality (VR) | VR នឹងជួយកាត់បន្ថយហានិភ័យ និងជួយសម្រួលដល់ការកំណត់បញ្ហាបានយ៉ាងឆាប់រហ័ស។ ប្រទេសមួយចំនួនដូចជាប្រទេសកូរ៉េខាងត្បូង, ប្រទេសសិង្ហបុរី, ប្រទេសចិន, ប្រទេសបារាំង, ប្រទេសអាឡឺម៉ង់, សហរដ្ឋអាមេរិក និងប្រទេសអង់គ្លេសប្រើបច្ចេកវិទ្យានេះ។ |  |
| ៨ | Augmented Reality (AR) | AR នឹងតាមដានការផ្លាស់ប្តូរនៅក្នុងផលិតកម្ម កំណត់លក្ខខណ្ឌផ្សេងៗ និងត្រួតពិនិត្យផលិតផលដែលបានបញ្ចប់ការផលិត។ ប្រទេសមួយចំនួនដូចជាប្រទេសចិន, ប្រទេសសិង្ហបុរី, ប្រទេសបារាំង,ប្រទេសកូរ៉េខាងត្បូង និងសហរដ្ឋអាមេរិកប្រើប្រាស់បច្ចេកវិទ្យានេះ។ |  |
| ៩ | Machine Learning & AI | សហភាពអឺរ៉ុប, ប្រទេសចិន, ប្រទេសជប៉ុន និងសហរដ្ឋអាមេរិកប្រើប្រាស់បច្ចេកវិទ្យានេះសម្រាប់ការវិភាគទិន្នន័យ ដែលមានលក្ខណៈស្មុគស្មាញ។ |  |

| ល.រ | បច្ចេកវិទ្យាឌីជីថល | ការអនុវត្ត | រូបតំណាង |
|---|---|---|---|
| ១០ | Data warehouse | សហភាពអឺរ៉ុប, សហរដ្ឋអាមេរិក និងប្រទេសចិនប្រើប្រាស់បច្ចេកវិទ្យានេះសម្រាប់ផ្ទុក និងវិភាគទិន្នន័យ ក៏ដូចជារាយការណ៍ព័ត៌មានដែលប្រមូលបាន។ |  |
| ១១ | Edge Computing | ប្រទេសចិន និងសហភាពអឺរ៉ុបប្រើប្រាស់បច្ចេកវិទ្យានេះសម្រាប់កាត់បន្ថយភាពស្មុគស្មាញនៃប្រព័ន្ធគ្រប់គ្រង ផ្តល់ភាពងាយស្រួលក្នុងការប្រមូល និងវិភាគទិន្នន័យ។ |   |
| ១២ | Robotics & Automation | សម្រាប់ជាជំនួយដល់កម្លាំងពលកម្ម។ ប្រទេសមួយចំនួន ដូចជាប្រទេសចិន, សហរដ្ឋអាមេរិក, ប្រទេសជប៉ុន, ប្រទេសអាឡឺម៉ង់ និងប្រទេសអង់គ្លេស បាននឹងកំពុងប្រើប្រាស់បច្ចេកវិទ្យានេះ។ |   |
| ១៣ | 5G | បណ្តាញអ៊ីនធឺណិតដែលមានល្បឿនលឿន នឹងកាត់បន្ថយភាពយឺតយ៉ាវ ជួយពន្លឿនទំនាក់ទំនង។ ប្រទេសមួយចំនួនដូចជាប្រទេសជប៉ុន, ប្រទេសកូរ៉េខាងត្បូង, ប្រទេសចិន, ប្រទេសកាណាដា និងប្រទេសអង់គ្លេស បាននឹងកំពុងប្រើប្រាស់បច្ចេកវិទ្យានេះ។ |  |

| ល.រ | បច្ចេកវិទ្យាឌីជីថល | ការអនុវត្ត | រូបតំណាង |
|---|---|---|---|
| ១៤ | SAP integration | ប្រទេសចិន, ប្រទេសជប៉ុន, ប្រទេសបារាំង និងប្រទេសអាឡឺម៉ង់ ប្រើប្រាស់បច្ចេកវិទ្យានេះសម្រាប់កំណត់សមត្ថភាពផលិត, កំណត់ពេលវេលាផលិត និងលទ្ធភាពដែលអាចផលិតបាន។ |  |
| ១៥ | ERP integration (Enterprise Resources Planning) | ប្រទេសឥណ្ឌាប្រើប្រាស់បច្ចេកវិទ្យានេះសម្រាប់ព្យាករណ៍ពីតម្រូវការផលិតផលឲ្យកាន់តែមានភាពត្រឹមត្រូវ ដែលអាចកាត់បន្ថយថ្លៃស្តុកនៅពេលដែលមានការផលិតលើសកំណត់។ |  |
| ១៦ | Extreme Operational Efficiency Technology | គឺជាប្រព័ន្ធគ្រប់គ្រង និងថែរក្សាគ្រឿងម៉ាស៊ីន។ ដោយមានបំពាក់ Sensors នៅផ្នែកខាងក្នុងម៉ាស៊ីន វានឹងផ្តល់ព័ត៌មាននៅពេលម៉ាស៊ីនមានបញ្ហា ឬដល់ពេលត្រូវជួសជុល។ ប្រទេសមួយចំនួនប្រើប្រាស់បច្ចេកវិទ្យានេះ ដូចជាសហភាពអឺរ៉ុប, សហរដ្ឋអាមេរិក, ប្រទេសចិន និងប្រទេសឥណ្ឌា។ |  |
| ១៧ | Digital Twin | ប្រទេសអាឡឺម៉ង់ និងសហរដ្ឋអាមេរិកប្រើប្រាស់បច្ចេកវិទ្យានេះសម្រាប់ជម្រុញប្រព័ន្ធប្រតិបត្តិការនៅផ្នែកខាងក្នុងផលិតកម្ម, ធ្វើការព្យាករ, កែច្នៃ, ស្រាវជ្រាវ និងធ្វើតេស្តសាកល្បងគម្រូផលិតផល (Prototype)។ |  |

| ល.រ | បច្ចេកវិទ្យាឌីជីថល | ការអនុវត្ត | រូបតំណាង |
|---|---|---|---|
| ១៨ | MES (Manufacturing Execution System) | សម្រួលដល់ការបញ្ជាទិញវត្ថុធាតុដើម និងជួយសម្រួលដំណើរការផលិត។ ប្រទេសកូរ៉េខាងត្បូង, ប្រទេសឥណ្ឌា, ប្រទេសអាឡឺម៉ង់ និងសហរដ្ឋអាមេរិក បានប្រើប្រាស់បច្ចេកវិទ្យានេះ។ |  |
| ១៩ | Internet of Things (IoT) | ការតភ្ជាប់រវាងឧបករណ៍អេឡិចត្រូនិក ដែលអនុញ្ញាតិឱ្យឧបករណ៍ទាំងនោះ មានទំនាក់ទំនងគ្នា ផ្តល់សញ្ញា និង ជូនដំណឹងឱ្យគ្នានៅពេលមានបញ្ហា ណាមួយនៅក្នុងដំណើរការផលិត។ ប្រទេសមួយចំនួនប្រើប្រាស់ បច្ចេកវិទ្យា នេះរួមមានដូចជាប្រទេសចិន និង សហភាពអឺរ៉ុបជាដើម។ |  |

## *II. ជំនាញឌីជីថល*

### *ក. កម្រិតមូលដ្ឋាន*

*កម្រិតមូលដ្ឋានសម្រាប់អ្នកប្រើប្រាស់ទូទៅ នៅក្នុងវិស័យឧស្សាហកម្ម អាចជាប្រជាជនទូទៅនិង/ឬ បុគ្គលិកដែលបម្រើការនៅតាមក្រសួង-ស្ថាប័ន សហគ្រាសឯកជន និងរោងចក្រ ដែលមានកម្រិតចំណេះដឹង និងជំនាញឌីជីថលតិចតួច។*

| ល.រ | ប្រភេទជំនាញ | វត្ថុបំណង |
|---|---|---|
| ១ | អក្ខរកម្មឌីជីថល (Digital Literacy) | ចំណេះដឹងមូលដ្ឋានអំពីរបត់បច្ចេកវិទ្យា |
| ២ | ប្រតិបត្តិការបច្ចេកវិទ្យា (Technology Operation) | ភាពស្ទាត់ជំនាញក្នុងការប្រើប្រាស់ បច្ចេកវិទ្យាឌីជីថលដែលពាក់ព័ន្ធទៅនឹង វិស័យឧស្សាហកម្ម |
| ៣ | ឧបករណ៍វៃឆ្លាត (Smart Devices) | អាចប្រើប្រាស់មុខងារផ្សេងៗ ក្នុងប្រតិបត្តិការដោយប្រើប្រាស់ឧបករណ៍វៃឆ្លាត |
| ៤ | Search Engine | ការស្វែងរកព័ត៌មានតាមប្រព័ន្ធអ៊ីនធឺណិត |

## ខ. កម្រិតមធ្យម

សម្រាប់បុគ្គលិកដែលបម្រើការនៅតាមក្រសួង-ស្ថាប័ន សហគ្រាសឯកជន និងរោងចក្រ ដែលមានចំណេះដឹង និងជំនាញឌីជីថលកម្រិតមធ្យម ដោយអាចប្រើប្រាស់មុខងារនៃបច្ចេកវិទ្យាឌីជីថលដែលមានភាពស្មុគស្មាញមួយចំនួន និងមុខងារពិសេសៗមួយចំនួនផ្សេងទៀតបាន។

| ល.រ | ប្រភេទជំនាញ | វត្ថុបំណង |
| --- | --- | --- |
| ១ | ការគ្រប់គ្រងទិន្នន័យ (Data Management) | ការគ្រប់គ្រងព័ត៌មាន និងទិន្នន័យ |
| ២ | ការវិភាគ (Analytical Skills) | វិភាគទិន្នន័យ ឬព័ត៌មាន និងព្យាករណ៍ស្ថានភាព |
| ៣ | Digital Communication | ការទំនាក់ទំនងតាមប្រព័ន្ធឌីជីថល |
| ៤ | ការវិភាគ និងគ្រប់គ្រងហានិភ័យ (Risk Analysis & Risk Management) | ព្យាករណ៍ និងគ្រប់គ្រងហានិភ័យ ដោយប្រើប្រាស់ឧបករណ៍ឌីជីថល |
| ៥ | ការរចនាក្រាហ្វិក និងឌីសាញ (Graphics Design & Design) | ការឌីសាញ និងរចនាក្រាហ្វិក ដើម្បីផ្សព្វផ្សាយអំពីផលិតផល |
| ៦ | សហគ្រិនឌីជីថល (Digital Enterpreneurship) | បណ្តុះជំនាញសហគ្រិនឌីជីថល ដើម្បីឲ្យសហគ្រិនកាន់តែមានភាពច្នៃប្រឌិត និងប្រើប្រាស់បច្ចេកវិទ្យានៅក្នុងអាជីវកម្ម |

## គ. កម្រិតខ្ពស់

ជំនាញឌីជីថលកម្រិតខ្ពស់សម្រាប់បុគ្គលិកជំនាញផ្នែកព័ត៌មានវិទ្យា ក៏ដូចជាផ្នែកពាក់ព័ន្ធមួយចំនួនផ្សេងទៀត ដែលភាគីពាក់ព័ន្ធទាំងនោះមានចំណេះដឹង និងជំនាញឌីជីថលកម្រិតខ្ពស់ អាចប្រើប្រាស់មុខងារដែលមានភាពស្មុគស្មាញ ក៏ដូចជាអាចបង្កើតមុខងារ ឬកម្មវិធីថ្មីបានដោយខ្លួនឯង។

| ល.រ | ប្រភេទជំនាញ | វត្ថុបំណង |
|---|---|---|
| ១ | ការសរសេរកូដកម្មវិធី | សរសេរកូដកម្មវិធីគ្រប់គ្រង ឬបង្កើតកម្មវិធីថ្មីៗ |
| ២ | Software Programming & Software Development | ការបង្កើតកម្មវិធីឌីជីថល ការធ្វើតេស្ត និងការដោះស្រាយកំហុស |
| ៣ | ប្រព័ន្ធសុវត្ថិភាព (Security Program) | អាចបង្កើតប្រព័ន្ធសុវត្ថិភាព ក្នុងការគ្រប់គ្រងទិន្នន័យ ក៏ដូចជាប្រព័ន្ធគ្រប់គ្រងផ្សេងៗ |
| ៤ | Data Science & Data Analytics | ជំនាញក្នុងការវិភាគ និងបកស្រាយទិន្នន័យ |

*ជំនាញឌីជីថលទាំងអស់ដែលបានរៀបរាប់ខាងលើគួរយកមកបណ្តុះបណ្តាល និងបញ្ជ្រាបការយល់ដឹងដល់គ្រប់ភាគីពាក់ព័ន្ធទាំងអស់ រួមមានបុគ្គលិកនៅតាមក្រសួង-ស្ថាប័ន រោងចក្រ-សហគ្រាស សហគ្រិន និងប្រជាពលរដ្ឋទូទៅ។ ដោយឡែកចំពោះជំនាញកម្រិតខ្ពស់ គឺសម្រាប់ផ្តល់ការបណ្តុះបណ្តាលតែចំពោះបុគ្គលិកជំនាញ ដែលធ្វើការពាក់ព័ន្ធទៅនឹងវិស័យឧស្សាហកម្មវៃឆ្លាតប៉ុណ្ណោះ។*

## *សន្និដ្ឋាន*

*សរុបមក សម្រាប់ដំណាក់កាលក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩ យើងគួរបន្តជំរុញការអភិវឌ្ឍធនធានមនុស្សបន្ថែមទៀត ទាំងផ្នែកចំណេះដឹង និងជំនាញ ក៏ដូចជាសមត្ថភាពចាំបាច់ផ្នែកបច្ចេកវិទ្យា ដើម្បីអាចប្រើប្រាស់ជាជំនួយក្នុងការពន្លឿនការអភិវឌ្ឍវិស័យឧស្សាហកម្មវៃឆ្លាតនៅកម្ពុជា។ ជាមួយគ្នានេះដែរ បណ្តាញទូរគមនាគមន៍ ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធគាំទ្រជាមូលដ្ឋានផ្សេងទៀត ដូចជា បណ្តាញអគ្គិសនី និងអ៊ីនធឺណិតនៅតាមបណ្តារាជធានី-ខេត្ត ក៏សុទ្ធតែមានសារៈសំខាន់ និងភាពចាំបាច់សម្រាប់ជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្មវៃឆ្លាតនៅកម្ពុជាឱ្យទទួលបានជោគជ័យនាពេលខាងមុខ៕*

# ឯកសារយោង


1. 5 Must-Know Manufacturing Industry Trends for 2021, Beekeeper, ចូលអានថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២០ https://www.beekeeper.io/blog/manufacturing-trends/
2. All About Digital Transformation in the Manufacturing Industry, OROCommerce, ចូលអានថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២០ https://oroinc.com/b2b-ecommerce/blog/digital-transformation-in-manufacturing/
3. Digital Factories 2020, Shaping the future of manufacturing, pwc, ចូលអានថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២០
4. Industry 4.0: 7 Real-World Examples of Digital Manufacturing in Action, AMFG, ចូលអានថ្ងៃទី២០ ខែសីហា ឆ្នាំ២០២០https://amfg.ai/2019/03/28/industry-4-0-7-real-world-examples-of-digital-manufacturing-in-action/
5. Smart Factory Trends 2020 by Tanja Rauniaho-Mitchell, Elisa Smart Factory, ចូលអានថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២០ https://www.elisasmartfactory.com/smart-factory-trends-2020/
6. Technology and Skills in the digital industries, UK CES, ចូលអានថ្ងៃទី១៥ ខែសីហាឆ្នាំ២០២០
7. The impact of digital technology and Industry 4.0 on the ripple effect and supply chain risk analytics, Taylor & Francis Online, ចូលអានថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២០ https://www.tandfonline.com/doi/full/10.1080/00207543.2018.1488086
8. The Top 5 Digital Transformation Tools Manufacturers Are Leveraging, Chief Executive, ចូលអានថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២០ https://chiefexecutive.net/top-5-digital-transformation-manufacturing/


---

www.cambodia4point0.org

កម្ពុជា ៤.0 - Cambodia 4.0

cambodia_4.0

កម្ពុជា ៤.0 - Cambodia 4.0

cambodia4point0

កម្ពុជា ៤.0 - Cambodia 4.0